ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា
លេខ:.......០០៣/១១...គ.ម.ក ប្រ.ក.

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យអនុវត្តវិធានសមាជិកភាព

*****

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០១១ គមក.ប្រក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការផ្តល់ការអនុញ្ញាតឱ្យធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ



Downloaded from http://www.khmerlaws.com

- បានឃើញប្រកាសលេខ ០០៤ គមក.ប្រក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ស្តីពីខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ
- បានឃើញសំណើសុំការពិនិត្យ និងអនុម័ត លើវិធានសមាជិកភាព របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១០
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី ១១ ខែមេសា ឆ្នាំ២០១១

# ស ម្រ េ ច

**ប្រការ ១.-**

ដាក់ឱ្យអនុវត្តនូវវិធានសមាជិកភាព របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ២.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ នាយកដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សមាជិកនិងអ្នកចូលរួមក្នុងទីផ្សារមូលបត្រកម្ពុជា ព្រមទាំងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ២០១១

**គាត ឈន់**

**កន្លែងទទួល ÷**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ២
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



Downloaded from http://www.khmerlaws.com

ឧបសម្ព័ន្ធប្រកាសលេខ ០០៣/១១ គ.ម.ក. ប្រ.ក.

ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១១

# វិធានសមាជិកភាព

# របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

*****

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.- គោលបំណង**

គោលបំណងនៃវិធាននេះគឺដើម្បីកំណត់អំពីគោលការណ៍នានា ដែលចាំបាច់សម្រាប់ការគ្រប់គ្រងសមាជិកភាព និងការចូលរួមទាំងអស់នៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (សរសេរកាត់ថា **ផ.ម.ក.**) ដែលរួមទាំងការកំណត់គុណវុឌ្ឍិនៃសមាជិកភាព និងការចូលរួម ការផ្តល់ និងការដកសមាជិកភាពនិងការចូលរួម និងការកំណត់សិទ្ធិនិងកាតព្វកិច្ចរបស់សមាជិក និងអ្នកចូលរួម ដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**ប្រការ ២.- និយមន័យ**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងវិធាននេះ ត្រូវបានកំណត់នៅក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**-សមាជិកនិងអ្នកចូលរួម** សំដៅដល់សមាជិក ឬអ្នកចូលរួមទាំងឡាយណាដែលត្រូវអនុញ្ញាតឱ្យប្រើប្រាស់សេវារបស់ **ផ.ម.ក.** ទាំងស្រុង ឬមួយផ្នែក ស្របតាមប្រភេទសមាជិក ឬអ្នកចូលរួម។

**-សមាជិក** សំដៅដល់ក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណពីគណៈកម្មការមូលបត្រកម្ពុជា (សរសេរកាត់ថា **គ.ម.ក.**)ហើយជាសមាជិករបស់ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ និងមានសិទ្ធិប្រើប្រាស់ទាំងស្រុងនូវប្រព័ន្ធជួញដូរមូលបត្រ ប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្ររបស់ **ផ.ម.ក.**។



Downloaded from http://www.khmerlaws.com

-**អ្នកចូលរួម** សំដៅដល់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់-ងារចុះបញ្ជីផ្ទេរមូលបត្រ ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រជាដើម ដែលមានសិទ្ធិប្រើប្រាស់តែមួយផ្នែកនូវប្រព័ន្ធ ឬសេវារបស់ **ផ.ម.ក.**។

## ជំពូកទី ២
## ការចូលជាសមាជិក ឬអ្នកចូលរួម

### ប្រការ ៣.- នីតិវិធីដើម្បីចូលជាសមាជិក ឬអ្នកចូលរួម

បុគ្គលដែលទទួលបានអាជ្ញាបណ្ណ ឬបុគ្គលដែលទទួលបានការទទួលស្គាល់ចាំបាច់ ពី **គ.ម.ក.** ដែលមានបំណងចូលជាសមាជិក ឬជាអ្នកចូលរួមនៃ **ផ.ម.ក.** ត្រូវបំពេញបែបបទដើម្បីចូលជាសមាជិកឬអ្នកចូលរួមរបស់ **ផ.ម.ក.** ហើយត្រូវបញ្ជាក់ពីភាពមានគុណវុឌ្ឍិគ្រប់គ្រាន់ដូចមានកំណត់នៅក្នុងវិធាននេះ។

### ប្រការ ៤.- លក្ខខណ្ឌគុណវុឌ្ឍិ

លក្ខខណ្ឌគុណវុឌ្ឍិមានដូចខាងក្រោម :

១-ត្រូវមាន ឬមានភស្តុតាងបញ្ជាក់ថានឹងមានឧបករណ៍និងប្រព័ន្ធព័ត៌មានវិទ្យាដែលអាចភ្ជាប់បណ្តាញជាមួយប្រព័ន្ធព័ត៌មានវិទ្យារបស់ **ផ.ម.ក.**។

២-ត្រូវមាន ឬមានភស្តុតាងបញ្ជាក់ថានឹងមានធនធានមនុស្សគ្រប់គ្រាន់ដើម្បីប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាដែលតភ្ជាប់បណ្តាញជាមួយប្រព័ន្ធព័ត៌មានវិទ្យារបស់ **ផ.ម.ក.** ស្របតាមលក្ខខណ្ឌតម្រូវដែលកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

### ប្រការ ៥.- ថ្លៃការអនុញ្ញាតសម្រាប់ការចូលជាសមាជិក ឬអ្នកចូលរួម

បុគ្គលដាក់ពាក្យស្នើសុំចូលជាសមាជិក ឬអ្នកចូលរួមត្រូវបង់ថ្លៃការអនុញ្ញាតដូចខាងក្រោម :

១-សមាជិកត្រូវបង់ថ្លៃការអនុញ្ញាតចូលជាសមាជិកសរុបចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀលសម្រាប់សមាជិកនៃប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ។

២-អ្នកចូលរួមត្រូវបង់ថ្លៃការអនុញ្ញាតជា ÷

ក-ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រចំនួន ៥.០០០.០០០ (ប្រាំលាន) រៀល។

ខ-ភ្នាក់ងារបញ្ជិកាមូលបត្រចំនួន ២.០០០.០០០ (ពីរលាន)រៀល។

គ-ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រចំនួន ២.០០០.០០០ (ពីរលាន) រៀល។



Downloaded from http://www.khmerlaws.com

ឃ- ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ ត្រូវបានលើកលែងការបង់ថ្លៃសម្រាប់ការអនុញ្ញាតធ្វើជាអ្នកចូលរួម។

## ជំពូកទី ៣
## ការដកហូតសមាជិកភាព ឬការចូលរួម

**ប្រការ ៦.- ការដកសមាជិកភាព ឬការចូលរួម ដោយស្ម័គ្រចិត្ត**

ក្នុងករណីដែលសមាជិក ឬអ្នកចូលរួមណាមួយមានបំណងស្នើសុំដកសមាជិកភាព ឬការចូលរួមរបស់ខ្លួន បុគ្គលនោះត្រូវដាក់សំណើសុំដកសមាជិកភាព ឬការចូលរួមទៅ **ផ.ម.ក.**។

ការដកសមាជិកភាព ឬការចូលរួម ព្រមទាំងកាលបរិច្ឆេទសុពលភាពនៃការដកសមាជិកភាពឬការចូលរួមត្រូវសម្រេចដោយ **ផ.ម.ក.**។

**ប្រការ ៧.- ការដកហូតសមាជិកភាព ឬការចូលរួម**

**ផ.ម.ក.** នឹងចាត់នីតិវិធីដកសមាជិកភាព ឬបញ្ឈប់ការចូលរួមពីសមាជិក ឬអ្នកចូលរួម ក្នុងករណីដែលសមាជិក ឬអ្នកចូលរួមនោះស្ថិតក្នុងស្ថានភាពដូចខាងក្រោម÷

១- ការដកហូតអាជ្ញាបណ្ណ ឬការទទួលស្គាល់ដើម្បីធ្វើអាជីវកម្មមូលបត្រ ឬការផ្ទេរអាជីវកម្ម ឬការបិទអាជីវកម្ម។

២- ការរំលាយក្រុមហ៊ុន។

៣- ការដកហូតសមាជិកភាព ឬការបញ្ឈប់ការចូលរួម។

**ប្រការ ៨.- ការផ្ទេរសមាជិកភាព ឬការចូលរួម**

បុគ្គលដែលមានបំណងផ្ទេរសមាជិកភាព ឬការចូលរួមដែលជាលទ្ធផលនៃការផ្ទេរអាជីវកម្ម ឬការរំលាយក្រុមហ៊ុនបញ្ចូលគ្នាជាដើម ត្រូវដាក់ពាក្យស្នើសុំផ្ទេរសមាជិកភាព ឬការចូលរួមទៅ **ផ.ម.ក.**។

សមាជិកភាព ឬការចូលរួមដែលត្រូវបានផ្ទេរស្របតាមកថាខណ្ឌទី ១ អាចត្រូវបានប្រគល់ឱ្យក្រុមហ៊ុនដែលនៅបន្តដំណើរការ ឬក្រុមហ៊ុនដែលត្រូវបានបង្កើតថ្មី ដោយមានការយល់ព្រមពី **ផ.ម.ក.**។

ក្នុងករណីដែលមានការផ្ទេរសមាជិកភាពស្របតាមកថាខណ្ឌទី ១ រាល់ការជួញដូរមូលបត្រទាំងឡាយដែលមិនបានទូទាត់របស់សមាជិកនោះ ត្រូវចាត់ទុកថាជាការជួញដូរដោយក្រុមហ៊ុនដែលនៅបន្តដំណើរការ ឬក្រុមហ៊ុនដែលត្រូវបានបង្កើតថ្មី។

**ប្រការ ៩.- ការបញ្ចប់ និងការផ្តល់សមាជិកភាព ឬការចូលរួមជាថ្មី**

សមាជិកភាព ឬការចូលរួមត្រូវមានសុពលភាពរយៈពេល ០២ (ពីរ) ឆ្នាំ គិតចាប់ពីថ្ងៃដែលសមាជិក-



Downloaded from http://www.khmerlaws.com

ភាពឬការចូលរួមត្រូវបានសម្រេចដោយ **ផ.ម.ក.**។ សមាជិកភាព ឬការចូលរួមដែលត្រូវបានបន្តថ្មីនឹងមានសុពលភាពរយៈពេល ០៣(បី) ឆ្នាំ គិតចាប់ពីថ្ងៃដែលសុពលភាពចាស់ផុតកំណត់។

សមាជិក ឬអ្នកចូលរួមដែលមានបំណងបន្តសមាជិកភាពរបស់ខ្លួន ត្រូវបំពេញបែបបទដើម្បីបន្តសុពលភាពយ៉ាងហោចណាស់ ៤៥ (សែសិបប្រាំ) ថ្ងៃ មុនថ្ងៃដែលសុពលភាពផុតកំណត់។

លក្ខខណ្ឌតម្រូវនានានៃការស្នើសុំបន្តសមាជិកភាព ឬការចូលរួម ត្រូវដូចគ្នានឹងលក្ខខណ្ឌតម្រូវនៃការស្នើសុំសមាជិកភាព ឬការចូលរួមលើកដំបូង ដែលមានចែងក្នុងប្រការ ៣ ខាងលើ។

ការស្នើសុំបន្តសមាជិកភាព ឬការចូលរួមស្របតាមកថាខណ្ឌទី ២ និងទី ៣ ខាងលើ ត្រូវសម្រេចដោយ **ផ.ម.ក.** និងត្រូវបង់ថ្លៃការអនុញ្ញាតចូលជាសមាជិកឬអ្នកចូលរួម ស្របតាមប្រការ ៥ នៃវិធាននេះ។

សេចក្ដីសម្រេចផ្ដល់ការអនុញ្ញាតបន្តធ្វើជាសមាជិក ឬជាអ្នកចូលរួម ត្រូវផ្ដល់ដោយ **ផ.ម.ក.** បន្ទាប់ពីសមាជិក ឬអ្នកចូលរួម បានបំពេញបែបបទបន្តត្រឹមត្រូវ និងបានបង់ថ្លៃសេវាផ្សេងៗដូចមានចែងក្នុងវិធាននេះ។

**ប្រការ ១០.- ការព្យួរការជួញដូរ និងការទូទាត់លើការជួញដូរដែលមិនទាន់ទូទាត់**

ចំពោះបុគ្គលដែលបានដាក់ពាក្យស្នើសុំដកសមាជិកភាព ឬការចូលរួមរបស់ខ្លួនស្របតាមប្រការ ៦ ខាងលើ ឬក៏សមាជិកភាព ឬការចូលរួមរបស់ខ្លួនត្រូវបានដកហូតស្របតាមប្រការ ៧ ខាងលើ សមាជិក ឬអ្នកចូលរួមនោះ ត្រូវបានព្យួរការប្រើប្រាស់សេវារបស់ **ផ.ម.ក.** ចាប់ពីថ្ងៃដែលការដកហូតសមាជិកភាពឬការចូលរួមត្រូវបានសម្រេចជាផ្លូវការដោយ **ផ.ម.ក.**។

## ជំពូកទី ៤
## សិទ្ធិ និងភារកិច្ចរបស់សមាជិកនិងអ្នកចូលរួម

**ប្រការ ១១.- សិទ្ធិរបស់សមាជិក និងអ្នកចូលរួម**

សមាជិកនិងអ្នកចូលរួមមានសិទ្ធិប្រើប្រាស់សេវារបស់ **ផ.ម.ក.** សម្រាប់ការជួញដូរមូលបត្រ ការជាត់ទាត់និងទូទាត់មូលបត្រ និងការរក្សាទុកមូលបត្រ ស្របតាមការសម្រេចរបស់ **ផ.ម.ក.** ពាក់ព័ន្ធនឹងការបែងចែករវាងសមាជិកនិងអ្នកចូលរួម និងពាក់ព័ន្ធនឹងវិធានការវិន័យដូចមានចែងក្នុងវិធានរបស់ **ផ.ម.ក.** ដែលទទួលបានការអនុម័តដោយ **គ.ម.ក.**។

**ប្រការ ១២.- ការបង់ថ្លៃសេវា**

សមាជិក ឬអ្នកចូលរួម ដែលទទួលបានការអនុញ្ញាតពី **ផ.ម.ក.** ត្រូវបង់ថ្លៃសេវាប្រចាំឆ្នាំដូចខាងក្រោម :



Downloaded from http://www.khmerlaws.com

១- សមាជិកត្រូវបង់ថ្លៃសេវាប្រចាំឆ្នាំចំនួន ៥០.០០០.០០០ (ហាសិបលាន) រៀល ដល់ **ផ.ម.ក.** នៅមុនដំណាច់ឆ្នាំនីមួយៗ។

២- សម្រាប់អ្នកចូលរួមជា :

ក- ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ត្រូវបង់ថ្លៃសេវាប្រចាំឆ្នាំចំនួន ១០.០០០.០០០ (ដប់លាន) រៀល។

ខ- ភ្នាក់ងារបញ្ជិកាមូលបត្រត្រូវបង់ថ្លៃសេវាប្រចាំឆ្នាំចំនួន ២.០០០.០០០ (ពីរលាន) រៀល។

គ- ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រត្រូវបង់ថ្លៃសេវាប្រចាំឆ្នាំចំនួន ៤.០០០.០០០ (បួនលាន) រៀល។

ឃ- អ្នកចូលរួមជាក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ ត្រូវបានលើកលែងការបង់ថ្លៃសេវាប្រចាំឆ្នាំ។

សម្រាប់ឆ្នាំសារពើពន្ធដំបូងនៃការអនុញ្ញាតដំបូង សមាជិក ឬអ្នកចូលរួមត្រូវបង់ថ្លៃសេវាប្រចាំឆ្នាំ នៅពេលដែលទទួលបានការអនុញ្ញាតដោយគណនាផ្អែកលើចំនួនថ្ងៃដែលនៅសល់ រហូតដល់ចុងឆ្នាំសារពើពន្ធ។ សម្រាប់ឆ្នាំសារពើពន្ធបន្តបន្ទាប់ សមាជិកឬអ្នកចូលរួមត្រូវបង់ថ្លៃសេវាប្រចាំឆ្នាំនេះ ឱ្យបានមុនថ្ងៃទី ១៥ ខែ ធ្នូ នៃឆ្នាំសារពើពន្ធចាស់។

**ប្រការ ១៣.- ការទូទាត់លើការជួញដូរមូលបត្រ**

សមាជិក ត្រូវមានកាតព្វកិច្ចទូទាត់លើរាល់ប្រតិបត្តិការមូលបត្រដែលខ្លួនបានអនុវត្ត នៅក្នុងប្រព័ន្ធជួញដូររបស់ **ផ.ម.ក.**។

សមាជិក ត្រូវបានហាមឃាត់មិនឱ្យធ្វើការអនុញ្ញាតឱ្យភាគីទី ៣ ធ្វើការទូទាត់លើប្រតិបត្តិការមូលបត្រក្នុងនាមរបស់ខ្លួនឡើយ។

**ប្រការ ១៤.- ការអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិនានា**

សមាជិក និងអ្នកចូលរួមទាំងអស់ត្រូវអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីអាជីវកម្មមូលបត្រ ព្រមទាំងវិធានរបស់ **ផ.ម.ក.** ដែលរួមទាំងវិធានប្រតិបត្តិការទីផ្សារមូលបត្រ វិធានប្រតិបត្តិការជាត់ទាត់និងទូទាត់មូលបត្រ វិធានប្រតិបត្តិការរក្សាទុកមូលបត្រ ព្រមទាំងចំណាត់ការ ឬវិធានការផ្នែកវិន័យដែលត្រូវបានអនុវត្តស្របតាមច្បាប់និងបទប្បញ្ញត្តិនានា។

**ប្រការ ១៥.- កិច្ចព្រមព្រៀងផ្តល់សេវា**

នៅពេលបើកគណនី សមាជិកនិងអ្នកចូលរួម ត្រូវចុះកិច្ចព្រមព្រៀងផ្តល់សេវាជាមួយ **ផ.ម.ក.** តាមគំរូដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.**។



Downloaded from http://www.khmerlaws.com

សមាជិក និងអ្នកចូលរួមត្រូវផ្ដល់ជូន **ផ.ម.ក.** នូវគំរូនៃកិច្ចព្រមព្រៀងសេវារវាងសមាជិក ឬអ្នកចូលរួម និងអតិថិជនរបស់ខ្លួន ដែលបានបង្កើតឡើងស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធរបស់ **គ.ម.ក.**។

## ជំពូកទី ៥
## ការត្រួតពិនិត្យសមាជិក និងអ្នកចូលរួម

### ប្រការ ១៦.- របាយការណ៍អំពីស្ថានភាពហិរញ្ញវត្ថុ

សមាជិកត្រូវផ្ដល់ជូន **ផ.ម.ក.** នូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលបានធ្វើសវនកម្មរួច ព្រមទាំងព័ត៌មានផ្សេងទៀតដែលកំណត់ដោយ **គ.ម.ក.**។ អ្នកចូលរួមត្រូវផ្ដល់ជូន **ផ.ម.ក.** នូវរបាយការណ៍ និងព័ត៌មានដែលកំណត់ដោយ **គ.ម.ក.**។

### ប្រការ ១៧.- សំណើសុំផ្ដល់ព័ត៌មាន

**ផ.ម.ក.** អាចស្នើឱ្យសមាជិក និងអ្នកចូលរួមផ្ដល់នូវព័ត៌មានពាក់ព័ន្ធក្នុងករណីដូចខាងក្រោម :

១-ករណីដែលមានភាពចាំបាច់ក្នុងការបញ្ជាក់ឱ្យដឹងច្បាស់ថា សមាជិក និងអ្នកចូលរួមពិតជាបានអនុវត្តត្រឹមត្រូវតាមការណែនាំនៃវិធាននេះ ឬតាមកាតព្វកិច្ចរបស់ខ្លួន។

២-ករណីដែលមានភាពចាំបាច់ សម្រាប់ការគ្រប់គ្រងដំណើរការទីផ្សារប្រកបដោយរបៀបរៀបរយ។

### ប្រការ ១៨.- វិធានការវិន័យចំពោះសមាជិក និងអ្នកចូលរួម

ចំពោះសមាជិកនិងអ្នកចូលរួម ដែលមិនអនុវត្តតាមវិធានទាំងឡាយរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា **ផ.ម.ក.** អាចចាត់វិធានការវិន័យក្នុងចំណោមវិធានការដូចខាងក្រោម :

១-ការព្រមាន។

២-ការព្យួរសមាជិកភាព ឬការចូលរួមទាំងស្រុង ឬផ្នែកណាមួយ ដែលអាចមានក្នុងរយៈពេលកំណត់ណាមួយ។

៣-ការបញ្ឈប់ពីសមាជិកភាព ឬពីការចូលរួមនៃ **ផ.ម.ក.**។

### ប្រការ ១៩.- ការជូនដំណឹងអំពីការចាត់វិធានការ

នៅពេលដែលវិធានការដូចជាការបញ្ឈប់ ឬការព្យួរសមាជិកភាព ឬការចូលរួមទាំងស្រុងឬមួយផ្នែក ឬការព្យួរសិទ្ធិជួញដូរទាំងស្រុង ឬមួយផ្នែក ត្រូវបានអនុវត្តចំពោះសមាជិក ឬអ្នកចូលរួមណាមួយ ឬនៅពេល



Downloaded from http://www.khmerlaws.com

ដែលវិធានការដែលបានអនុវត្តត្រូវបានបញ្ចប់ ផ.ម.ក. ត្រូវផ្តល់ដំណឹងអំពីការណ៍នេះភ្លាមដល់សមាជិក និងអ្នកចូលរួមដទៃទៀត។

## ជំពូកទី ៦
## អន្តរប្បញ្ញត្តិ

**ប្រការ ២០.- សុពលភាពនៃសមាជិកភាព ឬការចូលរួមលើកទីមួយ**

សម្រាប់ការចូលជាសមាជិក ឬជាអ្នកចូលរួមលើកទីមួយ សមាជិកភាព ឬការចូលរួមត្រូវមានសុពល-ភាពស្មើនឹងសុពលភាពនៅមាននៃអាជ្ញាបណ្ណ ឬការទទួលស្គាល់ ដែលចេញដោយ **គ.ម.ក.** ហើយថ្លៃនៃការអនុញ្ញាតសម្រាប់ការចូលជាសមាជិក ឬអ្នកចូលរួមនេះត្រូវគិតជាប្រូរ៉ាតា (Pro Rata)។

*****



Downloaded from http://www.khmerlaws.com